# ក្រុមការងារអង្គការសង្គមស៊ីវិលរៀបចំទិវាសិទ្ធិមនុស្ស ១០ ធ្នូ

## សេចក្តីថ្លែងការណ៍រួម

### សង្គមស៊ីវិលនៅប្រទេសកម្ពុជាអបអរសាទរខួបលើកទី៦៣ នៃទិវាសិទ្ធិមនុស្សអន្តរជាតិ

### ១០ ធ្នូ ១៩៤៨ - ១០ ធ្នូ ២០១១

ថ្ងៃនេះ សង្គមស៊ីវិលនៅក្នុងប្រទេសកម្ពុជា រួមជាមួយនឹងព្រះរាជតំណាងរបស់ព្រះករុណាព្រះបរមនាថ នរោត្តម សីហមុនី, សមាជិកសភាជាតិ តំណាងរាជរដ្ឋាភិបាលកម្ពុជា តំណាងអង្គទូតប្រចាំព្រះរាជាណាចក្រកម្ពុជា និងប្រជាពលរដ្ឋ សូមចូលរួមអបអរសាទរយ៉ាងជ្រាលជ្រៅ និងប្រកបដោយសេចក្តីសោមនស្សជាខ្លាំង នៅក្នុងឱកាសទិវាសិទ្ធិមនុស្សអន្តរជាតិ ខួបលើកទី៦៣ នៃ សេចក្តីប្រកាសជាសាកលស្តីពីសិទ្ធិមនុស្ស (១០ ធ្នូ ១៩៤៨ — ១០ ធ្នូ ២០១១) នៅក្រោមពាក្យស្លោកមួយដែលមានអត្ថន័យថាៈ "***ឯករាជ្យភាពតុលាការ និង សេរីភាពបញ្ចេញមតិ គឺជា មូលដ្ឋានគ្រឹះនៃយុត្តិធម៌សង្គម និងការគោរពសិទ្ធិមនុស្ស***" នៅរាជធានីភ្នំពេញ នៃព្រះរាជាណាចក្រកម្ពុជា។

នៅក្នុងទិវានេះដ៏មានតំលៃ និងជាប្រវត្តិសាស្ត្រនេះ សង្គមស៊ីវិលកម្ពុជា សូមចូលរួមរំលឹកដឹងគុណដល់វិញ្ញាណក្ខន្ធរបស់អ្នកស្រលាញ់សិទ្ធិមនុស្ស សកម្មជនការពារសិទ្ធិមនុស្សទាំងអស់នៅក្នុងពិភពលោក ក៏ដូចជានៅក្នុងព្រះរាជាណាចក្រកម្ពុជា ដែលបានពុះពារការលំបាកទាំងឡាយ រួមមានការលះបង់អាយុជីវិត កំលាំងកាយ កំលាំងចិត្ត ក្នុងបុព្វហេតុលើកស្ទួយ និងការពារសិទ្ធិសេរីភាពរបស់មនុស្សជាតិ នាពេលកន្លងមក រហូតដល់សំរេចបាន សេចក្តីប្រកាសជាសាកល ស្តីពីសិទ្ធិមនុស្ស សំរាប់ជាមាគ៌ាគោរពប្រតិបត្តិដោយប្រជាជាតិទាំងអស់ មកទល់បច្ចុប្បន្ននេះ។

កាលពីថ្ងៃទី១០ ធ្នូ ឆ្នាំ១៩៤៨ មហាសន្និបាតអង្គការសហប្រជាជាតិ បានអនុម័ត សេចក្តីប្រកាសជាសាកល ស្តីពីសិទ្ធិមនុស្ស ដែលជាកម្រងឯកសារសិទ្ធិមនុស្សអន្តរជាតិ ដោយទទួលស្គាល់នូវតំលៃនៃសិទ្ធិ និងសេរីភាពជាមូលដ្ឋានរបស់មនុស្សទាំងអស់។ សេចក្តីប្រកាសនេះកំណត់ថា មនុស្សម្នាក់ៗអាចប្រើប្រាស់សិទ្ធិ និងសេរីភាពទាំងអស់ដោយគ្មានការរើសអើងនូវ ពូជសាសន៍ ពណ៌សម្បុរ ភេទ ភាសា សាសនា វប្បធម៌ មតិនយោបាយ ដើមកំណើតជាតិ ឬសង្គម ទ្រព្យសម្បត្តិ ឋានៈសង្គម និងស្ថានភាពឯទៀតៗ។ ចាប់តាំងពីត្រូវបានអនុម័តនៅឆ្នាំ១៩៤៨ រួចមក សេចក្តីប្រកាសនេះ ត្រូវបានចាត់ទុកថាជា "*បទដ្ឋានសាកលមួយ នៃសមិទ្ធផលរបស់មនុស្សគ្រប់ប្រជាជាតិទាំងអស់*"។

បើទោះបីជា កម្រងឯកសារសិទ្ធិមនុស្សនេះ ជាមូលដ្ឋានសំរាប់ការគោរព និងការលើកស្ទួយសិទ្ធិមនុស្សសំរាប់ប្រជាជាតិដែលជាសមាជិករបស់អង្គការសហប្រជាជាតិ ដែលចាប់កំណើតឡើងកាលពី៦២ឆ្នាំមុនក៏ដោយ ក៏សព្វថ្ងៃនេះ ការគោរព ការលើកស្ទួយ និងការការពារសិទ្ធិមនុស្សសំរាប់ប្រទេសជាសមាជិកមួយចំនួនធំនៅមាន

កំរិត ហើយស្ថានភាពរំលោភសិទ្ធិមនុស្ស និងការរើសអើងប្រឆាំងនឹងមនុស្សរាប់លាននាក់ នៅក្នុងពិភពលោក នៅតែបន្តកើតមាន ដែលចាំបាច់យើងទាំងអស់គ្នាតស៊ូពុះពារថែមទៀត ដើម្បីជំរុញឱ្យរដ្ឋជាភាគីទាំងអស់បន្ត លើកស្ទួយ និងគោរពឱ្យបានប្រសើរ ស្របទៅតាមកាតព្វកិច្ចរបស់ខ្លួន នៅក្រោមសេចក្តីប្រកាសជាសាកលនេះ ព្រមទាំងកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិមនុស្សដទៃទៀតៗ ដែលខ្លួនបានផ្តល់សច្ចាប័ន។

ព្រះរាជាណាចក្រកម្ពុជា ក្នុងឋានៈជារដ្ឋភាគីមួយនៅក្នុងអង្គការសហប្រជាជាតិ បានប្តេជ្ញាគោរពយ៉ាង ម៉ឺងម៉ាត់នូវកាតព្វកិច្ចរបស់ខ្លួន តាមរយៈការចែង និងការទទួលស្គាល់នូវសេចក្តីប្រកាសជាសាកល ស្តីពីសិទ្ធិមនុស្ស និងកតិកាអន្តរជាតិដទៃទៀត នៅក្នុងរដ្ឋធម្មនុញ្ញរបស់ខ្លួន។ ជាក់ស្តែង មាត្រា ៣១ ចែងថាៈ “*ព្រះរាជាណាចក្រកម្ពុជាទទួលស្គាល់ និងគោរពសិទ្ធិមនុស្សដូចមានចែងនៅក្នុងធម្មនុញ្ញនៃអង្គការសហប្រជាជាតិ សេចក្តីប្រកាសជាសាកលស្តីពីសិទ្ធិមនុស្ស និងកតិកាសញ្ញា ព្រមទាំងអនុសញ្ញាទាំងឡាយទាក់ទងទៅនឹង សិទ្ធិមនុស្ស សិទ្ធិនារី និងសិទ្ធិកុមារ*” ។

ដោយសារការទទួលស្គាល់ និងការផ្តល់សច្ចាប័នទៅលើសេចក្តីប្រកាសជាសាកលស្តីពីសិទ្ធិមនុស្ស និង កតិកាសញ្ញាស្តីពីសិទ្ធិមនុស្សមួយចំនួនទៀត ព្រះរាជាណាចក្រកម្ពុជា ជាពិសេស រាជរដ្ឋាភិបាលកម្ពុជាត្រូវមាន កាតព្វកិច្ចក្នុងការលើកស្ទួយ ការបំពេញ និងការគោរពសិទ្ធិមនុស្ស ដូចដែងមានចែងនៅក្នុងកម្រងឯកសារ សិទ្ធិមនុស្សទាំងនោះ ឱ្យបានពេញលេញ និងហ្មឺងម៉ាត់។ គិតរហូតមកទល់ពេលនេះ សង្គមស៊ីវិលនៅក្នុងប្រទេស កម្ពុជាបានកត់សំគាល់ឃើញថា មានភាពរីកចំរើនវិជ្ជមានមួយចំនួន ដូចជាៈ ការបន្តចូលរួមជារដ្ឋភាគីនៅក្នុង កតិកាសញ្ញាអន្តរជាតិ, ការចូលរួមនៅក្នុងវេទិកាតំបន់ តួយ៉ាង សមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ ហៅកាត់ថា “អាស៊ាន” ក្នុងឋានៈជាតំណាងមួយរូបនៅក្នុងគណៈកម្មការអន្តររដ្ឋាភិបាលសិទ្ធិមនុស្សអាស៊ាន, ការបង្កើត និង ការអនុម័តច្បាប់ ព្រមទាំងការជំរុញគុណភាព និងការបង្កើនប្រសិទ្ធភាពរបស់ស្ថាប័នអនុវត្តច្បាប់ឱ្យស្របទៅតាម ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ដែលជាគោលនយោបាយរបស់ប្រទេសជាតិ។

ទោះបីជាយ៉ាងណាក៏ដោយ សង្គមស៊ីវិលកម្ពុជា ក៏ឃើញមានចំណុចព្រួយបារម្ភជាច្រើនទៀតដូចជាៈ ភាពយឺតយ៉ាវក្នុងការកែទម្រង់ប្រព័ន្ធតុលាការឱ្យមានឯករាជ្យ និងសមត្ថភាពពេញលេញ, ការកសាងច្បាប់គ្រឹះ សំខាន់ៗនិងការអនុវត្តច្បាប់ឱ្យមានប្រសិទ្ធភាពដើម្បីការពារសិទ្ធិមនុស្ស, ការកើនឡើងនូវករណីរំលោភយកដីធ្លី និងការបណ្តេញប្រជាពលរដ្ឋពីលំនៅដ្ឋានដោយបង្ខំ, ការគំរាមកំហែង និងការរើសអើងប្រឆាំងនឹងសកម្មជន ការពារសិទ្ធិមនុស្ស និងអ្នកសំដែងមតិខុសគ្នានឹងរាជរដ្ឋាភិបាល តាមរយៈការប្រើប្រាស់យន្តការតុលាការ និង ការពង្រួញសិទ្ធិសេរីភាពក្នុងការបញ្ចេញមតិ និងការបញ្ចេញមតិតាមទីសាធារណៈ ។ល។ ក្រៅពីនេះ មានបញ្ហា រំលោភសិទ្ធិមនុស្សធ្ងន់ធ្ងរមួយចំនួនទៀត ដែលគួរឱ្យព្រួយបារម្ភផងដែរ ជាអាទិ៍ដូចជាៈ អំពើជួញដូរ និងអំពើកេង ប្រវ័ញ្ចទៅលើស្ត្រីភេទនិងកុមារ, ការរំលោភសិទ្ធិជនជាតិដើមភាគតិច, ការរើសអើង និងការរំលោភសិទ្ធិជនពិការ និងយោធិនពិការ និងការរំលោភបំពានសិទ្ធិកម្មករ-និយោជិតក្នុងការតវ៉ាទាមទារធ្វើកូដកម្ម និងបាតុកម្មដោយ សន្តិវិធី ជាដើម ។ល។

ដើម្បីឆ្លើយតបទៅនឹងការប្តេជ្ញាចិត្តរបស់កម្ពុជា ដែលបានទទួលស្គាល់ និងលើកស្ទួយសិទ្ធិមនុស្ស ដូចបាន ចែងរដ្ឋធម្មនុញ្ញ យើងខ្ញុំជាតំណាងសង្គមស៊ីវិលរៀបចំទិវាសិទ្ធិមនុស្ស សូមស្នើសុំ និងអំពាវនាវដល់រាជរដ្ឋាភិបាល កម្ពុជា ស្ថាប័នព្រឹទ្ធសភា រដ្ឋសភា ព្រមទាំងស្ថាប័នតុលាការ ដែលជាស្ថាប័នមានសមត្ថកិច្ចរបស់ជាតិ មេត្តាចាត់

វិធានការសំខាន់ៗ ដូចខាងក្រោមៈ

- បង្កើនល្បឿនក្នុងការធ្វើច្បាប់សំខាន់ៗដូចជាៈ ច្បាប់ស្តីពីវិសោធនកម្មឧត្តមក្រុមប្រឹក្សា នៃអង្គចៅក្រម, ច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃតុលាការ, ច្បាប់ស្តីពីលក្ខន្តិកៈចៅក្រម និងព្រះរាជអាជ្ញា និងច្បាប់ស្តីពីសិទ្ធិទទួលព័ត៌មាន ដើម្បីជំរុញល្បឿនក្នុងការកែទំរង់ប្រព័ន្ធតុលាការនិងច្បាប់ ព្រមទាំងធ្វើឱ្យប្រសើរឡើងនូវប្រសិទ្ធភាពក្នុងការអនុវត្តច្បាប់ដោយស្ថាប័នមានសមត្ថកិច្ច ក៏ដូចជាមន្ត្រីអនុវត្តន៏ច្បាប់គ្រប់លំដាប់ថ្នាក់ ។
- ជំរុញនូវការអនុវត្តន៏ច្បាប់ឱ្យមានប្រសិទ្ធភាព និងជំរុញឱ្យមានឯករាជ្យភាព និងអព្យាក្រឹតភាពរបស់ស្ថាប័នតុលាការគ្រប់ជាន់ថ្នាក់ ដើម្បីធានាឱ្យមានការកាត់ក្តីប្រកបដោយយុត្តិធម៌សំរាប់ប្រជាពលរដ្ឋទាំងអស់ ។
- ធានាឱ្យបានពេញលេញនូវការលើកស្ទួយនូវសិទ្ធិសេរីភាពក្នុងការសំដែងមតិ និងការជួបប្រជុំជាសាធារណៈដែលជាមូលដ្ឋានគ្រឹះក្នុងចូលរួមគ្រប់សកម្មភាពអភិបាលកិច្ចសាធារណៈរបស់រដ្ឋ ក៏ដូចជាជួយក្នុងសកម្មភាពលើកស្ទួយ និងការពារសិទ្ធិមនុស្ស នីតិរដ្ឋ និងលទ្ធិប្រជាធិបតេយ្យ ជាពិសេស ចៀសវាងការរឹតត្បិតតាមរយៈការបង្កើតឱ្យមានច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាលដ៏ចម្រូងចម្រាស់ ។ ម្យ៉ាងទៀត នៅពេលប្រទេសកម្ពុជាជាប្រធានសមាគមអាស៊ាននៅឆ្នាំ២០១២ ខាងមុខ រាជរដ្ឋាភិបាលគួរបើកលំហសិទ្ធិសេរីភាពឱ្យបានទូលំទូលាយនិងពេញលេញ សំរាប់ផ្តល់ឱកាសដល់អង្គការសង្គមស៊ីវិលជួបជុំសម្តែងមតិ និងលើកអនុសាសន៍ដាក់ជូនថ្នាក់ដឹកនាំអាស៊ានពិចារណា ដើម្បីធានាឱ្យមាននូវបរិយាកាសនៃការការពារ ការលើកស្ទួយ និងការគោរពសិទ្ធិមនុស្សនៅក្នុងតំបន់ ស្របទៅតាមធម្មនុញ្ញរបស់ខ្លួន ។
- បង្កើតគោលនយោបាយអភិវឌ្ឍន៏ជាតិ ដែលមិនរំលោភបំពានសិទ្ធិមនុស្ស និងធានានូវសេចក្តីសុខ និងផលប្រយោជន៏របស់ប្រជាពលរដ្ឋជាធំ ។
- បញ្ឈប់ការរើសអើងប្រឆាំងនឹងសកម្មជនការពារសិទ្ធិមនុស្សនានា ក្នុងការទាមទាររកយុត្តិធម៌ និងជួយការពារដល់ជនរងគ្រោះដោយសារអំពើរំលោភសិទ្ធិមនុស្សផ្សេងៗ ។
- រៀបចំឱ្យមានគោលនយោបាយដីធ្លីនិងលំនៅដ្ឋានច្បាស់លាស់ ដើម្បីធានាឱ្យមានលក្ខខណ្ឌសមស្របសំរាប់ការរស់នៅរបស់ប្រជាពលរដ្ឋជាអាទិ៍ៈ លំនៅដ្ឋានសមរម្យ, សេវាសុខភាព, ហេដ្ឋារចនាសម្ព័ន្ធ និងប្រព័ន្ធសិក្សាអប់រំ ។
- បញ្ឈប់ការជម្លៀសប្រជាពលរដ្ឋចេញពីលំនៅដ្ឋានដោយបង្ខំក្នុងបញ្ហាវិវាទដីធ្លី និងដីសហគមន៍នៅទូទាំងប្រទេស ក្នុងរូបភាជាការអនុវត្តន៏កម្មវិធីអភិវឌ្ឍន៏ជាតិ ។
- បញ្ឈប់ការប្រើប្រាស់កងកម្លាំងប្រដាប់អាវុធ ក្នុងការដោះស្រាយបញ្ហាជាមួយនឹងប្រជាពលរដ្ឋក្នុងវិវាទដីធ្លី ប៉ុន្តែត្រូវធានាក្នុងការបង្កើនសមត្ថភាពសំរាប់ការចចារដោយសន្តិវិធី និងអនុវត្តទៅតាមគោលការណ៏ច្បាប់ជាធរមាន ។
- លើកស្ទួយ និងគោរពសិទ្ធិកម្មករ-និយោជិត ជាពិសេស ពង្រឹងយន្តការដោះស្រាយវិវាទការងារប្រកបដោយសន្តិវិធី និងប្រសិទ្ធភាពខ្ពស់ ។
- ជំរុញឱ្យមានលើកស្ទួយនូវសមភាពយេនឌ័រនៅក្នុងវិស័យការងារសាធារណៈ និងលុបបំបាត់នូវរាល់ទំរង់

នៃការរើសអើងប្រឆាំងនឹងស្ត្រីភេទ ជាពិសេស សិទ្ធិក្នុងការចូលរួមសកម្មនៅក្នុងវិស័យនយោបាយ ។

- ការពារ និងលើកស្ទួយសិទ្ធិជនជាតិដើមភាគតិច ជនជាតិភាគតិច ដែលនៅរស់នៅក្នុងប្រទេសកម្ពុជា ឱ្យចៀសផុតអំពីការរើសអើងគ្រប់រូបភាព ។
- បង្ក្រាប និងលុបបំបាត់រាល់ទម្រង់នៃការជួញដូរ និងការកេងប្រវ័ញ្ចទៅលើស្ត្រី និងកុមារ ដោយអនុវត្តន៍ច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរ និងអំពើអាជីវកម្មភេទ ឱ្យបានហ្មត់ចត់ និងមានប្រសិទ្ធភាព ។
- ជំរុញឱ្យមានការអនុវត្តប្រកបដោយប្រសិទ្ធភាពនូវច្បាប់ស្តីពីកិច្ចការពារ និងលើកកំពស់សិទ្ធិជនពិការ និងផ្តល់សច្ចាប័នទៅលើអនុសញ្ញាអន្តរជាតិស្តីពី សិទ្ធិជនពិការ ដើម្បីការពារសិទ្ធិជនពិការ ។
- ទប់ស្កាត់រាល់ទំរង់នៃការរើសអើងចំពោះអ្នកផ្ទុកមេរោគអេដស៍/ហ៊ីវ ព្រមទាំងធានានូវឱកាសដល់ពួកគេក្នុងការចូលរួមសកម្មភាពសង្គមជាតិ ដូចពលរដ្ឋដទៃទៀត ។

*ភ្នំពេញ ថ្ងៃទី១០ ខែធ្នូ ឆ្នាំ២០១១*


<u>**សំរាប់ព័ត៌មានលំអិត សូមទំនាក់ទំនងៈ**</u>

| | | |
|---|---|---|
| លោក **ធន សារាយ** | ប្រធានសំរបសំរួល CHRAC/ប្រធានសមាគម ADHOC | ទូរស័ព្ទលេខៈ ០១៦ ៨៨០ ០៤៤ |
| លោក **ឈិត សំអាត** | នាយកប្រតិបត្តិ NGO Forum | ទូរស័ព្ទលេខៈ ០១២ ៩២៨ ៥៨៥ |
| លោក **សុក សំអឿន** | នាយកប្រតិបត្តិ CDP | ទូរស័ព្ទលេខៈ ០១២ ៩០១ ១៩៩ |
| លោកស្រី **ធិដា ឃី** | នាយកប្រតិបត្តិអង្គការ SILAKA | ទូរស័ព្ទលេខៈ ០១២ ៨៣៨ ៤៦៤ |
| លោក **អាត់ ធន់** | ប្រធានសហភាពការងារកម្ពុជា (CLC) | ទូរស័ព្ទលេខៈ ០១២ ៩៩៨ ៩០៦ |
| លោកស្រី **ជេត ចរិយា** | នាយិកាប្រតិបត្តិអង្គការស្តារកម្ពុជា | ទូរស័ព្ទលេខៈ ០១២ ៨០២ ៤៦០ |
| លោក **ងិន សៅរ័ត្ន** | នាយកប្រតិបត្តិអង្គការជនពិការកម្ពុជា (CDPO) | ទូរស័ព្ទលេខៈ ០១៦ ៨៥១ ៨៤១ |


-----------------------

## សមាជិកនៃក្រុមការងារនៃអង្គការសង្គមស៊ីវិលរៀបចំពិធីអបអរសាទរ<br>ទិវាសិទ្ធិមនុស្សអន្តរជាតិលើកទី៦៣

១- គណៈកម្មាធិការប្រព្រឹត្តិកម្ម នៃអង្គការ-សមាគមការពារសិទ្ធិមនុស្សកម្ពុជា (CHRAC)

២- វេទិកា នៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា (NGO Forum)

3- មេឌីខាំ (MEDiCAM )

៤- គណៈកម្មាធិការសហប្រតិបត្តិការដើម្បីកម្ពុជា (CCC)

5- គណៈកម្មាធិការសំរបសំរួលប្រយុទ្ធប្រឆាំងនឹងជំងឺអេដស៍ (HACC)

៦- អង្គការយេនឌ័រ និងអភិវឌ្ឍន៍ ដើម្បីកម្ពុជា (GADC)

៧- សហភាពការងារកម្ពុជា (CLC)

៨- គណៈកម្មាធិការដើម្បីលើកស្ទួយស្រ្តីនៅក្នុងវិស័យនយោបាយ （CPWP）

៩- គណៈកម្មាធិការលុបបំបាត់រាល់ទំរង់នៃការរើសអើងប្រឆាំងនារីភេទ（CEDAW）

១០- សម្ពន្ធ័អង្គការក្រៅរដ្ឋាភិបាល ដើម្បីដោះស្រាយបញ្ហាកេងប្រវ័ញ្ចផ្លូវភេទលើកុមារ ក្នុងប្រទេសកម្ពុជា（COSECAM）

១១- គណៈកម្មាធិការដើម្បីបោះឆ្នោតដោយសេរី និងយុត្តិធម៌នៅកម្ពុជា（COMFREL）

១២- ក្រុមការងារពិសេសសិទ្ធិលំនៅឋាន（HRTF）

១៣- គណៈកម្មាធិការអព្យាក្រឹត និងយុត្តិធម៌ដើម្បីបោះឆ្នោតដោយសេរី និងត្រឹមត្រូវនៅកម្ពុជា（NICFEC)

១៤- អង្គការ ផែកនៅកម្ពុជា（PACT-Cambodia）

១៥- វិទ្យាស្ថានតស៊ូមតិ និងគោលនយោបាយ（API）

១៦- អង្គការជនពិការកម្ពុជា（CDPO）

១៧- អង្គការស្តារកម្ពុជា（Star Kampuchea）

១៨- គណៈកម្មាធិការអង្គការមិនមែនរដ្ឋាភិបាលដើម្បីសិទ្ធិកុមារ（NGO CRC）

១៩- គណៈកម្មាធិការយុវជន ដើម្បីឯកភាព និងអភិវឌ្ឍន៍(YCUD)

២០- អង្គការអ៊ិកផាតកម្ពុជា（ECPAT Cambodia）

២១- សម្ព័ន្ធភាពប្រជាពលរដ្ឋដើម្បីគណនេយ្យភាពសង្គមនៅកម្ពុជា (CASA)

២២- អង្គការគាំទ្រសហគមន៍ជនជាតិដើមភាគតិច (ICSO)